# ការសំភាសន៍របស់ មៀច ពៅ

កៈ អ្នកដែរសំភាសន៍គេ ជាង ស៊ីអារ        ខៈ អ្នកដែរអោយគេសំភាសន៍ មៀច ពៅ

កៈ ចឹងជាដំបូងខ្ញុំអរគុណបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថា BYU ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិប្រជាជនខ្មែរ ដើម្បីអោយកូនចៅជំនាន់ក្រោយៗពួកគាត់បានស្គាល់ពីប្រវត្តិរបស់ដូនតាចឹងហាសបង ចឹងនៅពេលដែរខ្ញុំបានសំភាសន៍បងហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលា ដែរមានឈ្មោះថា www.cambodianoralhistories.byu.edu ចឹងហាសបង បាទចឹងសំរាប់បង តើបងយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរទេបង?

ខៈ បាទយល់ព្រម

កៈ បាទសំរាប់ខ្ញុំជាអ្នកសំភាសន៍បងខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំសំភាសន៍បងគឺនៅថ្ងៃទី25 ខែ1 ឆ្នាំ2018 ហាសបង ហើយការសំភាសន៍មួយនេះត្រូវរៀបចំឡើងនៅភូមិទី4 សង្កាត់ផ្សារដើមថ្កូវ ខ័ណ្ឌចំការមន នៅរាជធានីភ្នំពេញហាសបង ចុះសំរាប់បងឈ្មោះពេញរបស់បងមានឈ្មោះអីគេដែរបង?

ខៈ ខ្ញុំឈ្មោះ មៀច ពៅ

កៈ ឈ្មោះ មៀច ពៅណាបង ចុះមានឈ្មោះហៅផ្សេងទេបង?

ខៈ អត់មានទេ

កៈ ចុះកាលពីក្មេងមាននរណាហៅឈ្មោះបងអីផ្សេងទេបង?

ខៈ នៅក្រៅហៅសៅ

កៈ អូហៅសៅណាបង នឹងកាលនៅក្មេងក៏គេហៅចឹងដែរ?

ខៈ ហៅក្រៅហៅសៅនឹង នៅក្នុងបញ្ជីជាតិឈ្មោះមៀច ពៅ

កៈ អ៎ូបាទបងចុះបងសព្វថ្ងៃបងអាយុប៉ុន្មានដែរបង?

ខៈ ខ្ញុំអាយុ35ឆ្នាំ

កៈ អូ៎អាយុ35ឆ្នាំណាបង ចុះនៅថ្ងៃខែឆ្នាំកំណើតបងចាំទេបង?

ខៈ អត់ចាំទេ

កៈ ប៉ុន្តែបងដឹងតែបងកើតនៅឆ្នាំ1983ណាបង?

ខៈ បាទនឹងហើយ

កៈ ចុះឆ្នាំច័ន្ទគតិបងមានដឹងថាបងឆ្នាំអីគេដែរទេ?

ខៈ ខ្ញុំឆ្នាំជូត

កៈ អូ៎ឆ្នាំជូតណាបង ចុះសព្វថ្ងៃបងមានកូនប៉ុន្មាននាក់ដែរបង?

ខៈ មានកូនម្នាក់ ប៉ុន្តែគាត់មិនមែនកូនបង្កើតទេកូនប្ដីមុន

កៈ ប៉ុន្តែឥឡូវនឹងគាត់អាយុប៉ុន្មានដែរហើយ?

ខៈ អាយុ35ឆ្នាំហើយ

កៈ ប៉ុន្តែគាត់កូនហាស?

ខៈ សួរគេខ្ញុំមិនសូវដឹងដែរនឹង

កៈ អូ៎ចឹងហោសបង?

ខៈ នឹងកូនប្តីមុន

កៈ ចុះទីកន្លែងដែរបងកើតបងកើតនៅណាវិញបង?

ខៈ ខ្ញុំកើតនៅភ្នំពេញនឹងតែម្ដងនឹង

កៈ នៅភ្នំពេញនៅភូមិអី ឃុំអីគេបង?

ខៈ នៅសង្កាត់ចំការមនតែម្ដងនឹង

កៈ បងកើតនៅនឹងតែម្ដងហោសបង?

ខ៖ នៅផ្សារដើមថ្កូវនឹង

ក៖ នៅផ្សារដើមថ្កូវ ចុះបងមានបងប្អូនប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានបងប្អូន7នាក់

ក៖ អូបងមានបងប្អូន7នាក់ចុះបងជាកូនទីប៉ុន្មានដែរបង?

ខ៖ ខ្ញុំពៅគេបង្អស់នឹង

ក៖ អូពៅគេណាបង ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរបង?

ខ៖ ខ្ញុំមានស្រី1នាក់នឹង ប្រុស6នាក់

ក៖ អូបងអាចប្រាប់ឈ្មោះបងប្អូនរបស់បងបានទេបងមានចងចាំទេ?

ខ៖ ចាំតា

ក៖ បងគេបង្អស់មានឈ្មោះអីគេដែរបង?

ខ៖ បងគេបង្អស់ស្លាប់បាត់ហើយ

ក៖ ប៉ុន្តែគាត់មានឈ្មោះអីគេដែរបង?

ខ៖ ឈ្មោះ មៀច វី

ក៖ ឈ្មោះ មៀច វី ចុំបងទី2គាត់មានឈ្មោះអីគេដែរបង?

ខ៖ កាត់ឈ្មោះ កួន

ក៖ ឈ្មោះ កួន ចុះបងទី3គាត់ឈ្មោះអី?

ខ៖ បងទី3ឈ្មោះ ប្រុស

ក៖ ចុះបងទី4វិញ?

ខ៖ បងទី4ឈ្មោះទក

ក៖ ទី5បងពៅគេ?

ខ៖ អត់ទេទី5បងស្រីពៅនោះឈ្មោះ ណាក់ គេមានកូនស្រីតែមួយទេ

កៈ ដល់ពេលទី6បានបង?

ខៈ ខ្ញុំ៣គេ

កៈ អូបាទចុះបងមានចងចាំសាច់រឿងអីដែរនៅជាមួយពួកគាត់ទេបង?

ខៈ អត់បានចាំទាំងអស់

កៈ ប៉ុន្តែបងមានចងចាំថាធ្លាប់បានលេងបិទពួន រឺមួយលេងឡឹកឡអីធ្លាប់លេងទេបង?

ខៈ មានធ្លាប់តា

កៈ អូលេងឡឹកឡបាទបង?

ខៈ គប់វង់គប់អីនឹង

កៈ បាទមានផ្ទាត់កៅស៊ូអី?

ខៈ បាញ់ឃ្លីបាញ់អី លោតកៅស៊ូលោតអីនឹង

កៈ ប៉ុន្តែបងមានធ្លាប់លេងលោតកំពស់អីអត់?

ខៈ ធ្លាប់តា

កៈ បងធ្លាប់លេងម៉ឹកអីចឹងហាសបង?

ខៈ បាទធ្លាប់លេង

កៈ ចុំបងមានធ្លាប់ដើរលេងអីជាមួយបងប្អូនរបស់បងទេ ដូចជាដើរផ្សារដើរអីចឹងហាស រឺទៅសាលាទៅអីចឹងទៅ?

ខៈ ដើរផ្សារទៅម្នាក់អែងបានទៅ

កៈ ចឹងហោសបង?

ខៈ ធ្លាប់ទៅផ្សារ ធ្លាប់តៅគៀនស្វាយអីទៅរកស៊ីអីធ្លាប់ទៅ

កៈ បាទបងចុះទៅនឹងលក្ខណៈថាទោម្នាក់អែងរឺមួយក៏ទៅជាមួយបងៗដែរបង?

ខៈ ទៅជាមួយបង

កៈ ទៅជាមួយបងហោស?

ខៈ លក្ខណៈដកខ្ទារឈូក

កៈ ដកខ្ទារឈូកដើម្បីយកមកលក់មែនបង នៅណានៅគៀនស្វាយហោសបង?

ខៈ នៅគៀនស្វាយនឹង

កៈ អូយើងដកចឹងបានច្រើនទេបង?

ខៈ ដកបានមួយចានដែកៗៗ

កៈ អូបានមួយចានដែកហោសបង ចុះយើងចំណេញបានប៉ុន្មានដែរទៅបង?

ខៈ បានបន្តិចបន្តួចបាន20000-30000មុឺនៗៗនឹង យើងផាត់សាំង
ផាត់ហូបចុកអីទាំងអស់ហាស

កៈ យើងចំណេញបាន20000-30000មុឺន
ចុះយើងទៅនឹងបឹងរបស់យើងរឺមួយក៏បឹងរបស់គេដែរបង?

ខៈ យើងម៉ៅគេបង

កៈ អូម៉ៅគេហោសបង?

ខៈ បាទម៉ៅគេមួយហត្ថាមួយមួយលានចឹងទៅ
ហើយគាត់ម៉ៅជារៀងរាល់ឆ្នាំម៉ៅ3ហត្ថាអស់3លានចឹងទៅណា

កៈ អូដូចថាគាត់ម៉ៅចឹងទៅហើយគាត់ហៅយើងអោយទៅជួយដកចឹងទៅណាបង?

ខៈ បាទហៅទៅជួយដកចឹងទៅដើម្បីយកមកលក់

កៈ បាទបង ចុះកាលពីក្មេងបងចូលចិត្តធ្វើអីគេជាមួយបងប្អូនរបស់បងដែរបង?

ខៈ នៅដកឈូកដកអី នៅលក់ខ្ទារឈូកអីចឹងទៅ លក់ខ្សែកំប្លោកអីចឹងទៅណាបាទ
ប្រវត្តិរបស់ខ្ញុំមានភាពជូរចង់អស់ហើយនឹង

កៈ
ចុះបងអាចមានចូលចិត្តធ្វើជាមួយពួកគាត់អីផ្សេងជាមួយពួកគាត់ទៀតបងអាចប្រាប់បានទេបង?

ខៈ អត់មានទេ

កៈ ដូចជាលេងបិទពួនលេងអីចឹងហាសកាលពីបងនៅក្មេងហាសបង?

ខៈ ខ្ញុំមានត្រូវលេងអីជាមួយគាត់ពីព្រោះគាត់ជាបងរបស់យើងនឹង
ប៉ុន្តែបើពេលនៅក្មេងលេង

កៈ អត់ទេចង់និយាយកាលពីក្មេងហាសបង?

ខៈ បាទនៅក្មេងលេងជាមួយក្មេងៗនឹងលេងជាមួយបងម៉េចកើតទៅ
លេងជាមួយក្មេងនៅម្តុំនឹងលេងជាមួយលេងក្មេងអ្នកជិតខាងនឹង

កៈ អូបាទបង ចុះបងៗរបស់បងគាត់ឥឡូវគាត់នៅណាដែរបង?

ខៈ គាត់នៅបឹងត្របែកទាំងអស់នឹង

កៈ ម៉ាក់របស់បងនឹងបងៗគឺនៅនឹងទាំងអស់?

ខៈ អត់ទេនៅខេត្តនៅនឹងតែបងស្រីនឹងកូនមួយគត់នឹងនៅភ្នំពេញនឹង

កៈ ចុះបងធំគាត់ស្លាប់នៅពេលណាដែរបង?

ខៈ យូរឆ្នាំដែរហើយបង ប្រហែលជា10ឆ្នាំហើយ

កៈ ចុះបងទី2គាត់នៅណាដែរបង?

ខៈ បងទី2នៅកោះធំ

កៈ អូនៅកោះធំចុះគាត់នៅធ្វើអីគេនៅកោះធំដែរបង?

ខៈ គាត់នៅលក់បន្លែអីចឹងទៅ

កៈ ឥឡូវហោស ចុះបងទី3គាត់ធ្វើអីគេដែរបង?

ខៈ ខ្ញុំមិនសូវដឹងដែរបងពួកគាត់នៅខេត្តៗដែរខ្ញុំមិនសូវដឹងទេ

កៈ ប៉ុន្តែបងទី3នៅខេត្តណាដែរបង?

ខៈ ខ្ញុំមិនសូវដឹងដែរនឹងលោកគ្រូ ស្គាល់តែបងនៅកោះធំមួយ

កៈ ចុះបងទី4វិញបង?

ខៈ នៅកំពុងស្ពឺ នឹងនៅភ្នំពេញយើងនេះក្រៅពីនឹងខ្ញុំអត់ដឹងទេ
មិនដឹងថាគាត់រកអីនៅណាទេ

កៈ ចុះបងស្រីក៏មិនដឹងថានៅណាដែរ?

ខៈ បងស្រីនៅភ្នំពេញនឹងទេ

កៈ គាត់នៅភ្នំពេញនឹងហោសបង?

ខៈ នឹងហើយខ្ញុំមានបងស្រីតែមួយគត់នឹង

កៈ អូគាត់នៅណាវិញបង?

ខៈ នេះគាត់នៅបឹងត្របែកយើងនឹង

កៈ គាត់នៅបឹងត្របែកគាត់ធ្វើអីគេដែរបង?

ខៈ គាត់នៅលក់មាន់

កៈ គាត់លក់មាន់ណបង ហើយគាត់យកទៅលក់នៅផ្សារទៅ?

ខៈ គាត់យកទៅលក់នៅផ្សារគីឡូលេខ6ហោស

កៈ អូនៅគីឡូលេខ6ឆ្ងាយហាសនេះបង ?

ខៈ នៅជិតផ្លូវរទេះភ្លើងហោស នៅជិតទួលគោកហោស

កៈ ចុះម្ដាយរបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ ម្ដាយរបស់ខ្ញុំគាត់ចាស់ដែរហើយនឹងគាត់នៅជាមួយកូននៅកោះធំហោស

កៈ បាទប៉ុន្តែគាត់មានឈ្មោះអីគេដែរបង?

ខៈ គាត់មានឈ្មោះយាយ យ៉ន

កៈ គាត់មានឈ្មោះយាយ យ៉ន?

ខៈ ពីដំបូងគាត់នៅជាមួយខ្ញុំដល់ពេលខ្ញុំអត់មានសមត្ថភាពទៅ ខ្ញុំចិញ្ចឹមគាត់មិនរស់ ខ្ញុំអត់មានសមត្ថភាពដល់ពេលចឹងទៅខ្ញុំបានបញ្ជូនគាត់អោយទៅកោះធំនឹង បាទទៅបានប្រហែលជាជិតមួយអាទិត្យហើយបង

កៈ អូចុះគាត់អាយុប៉ុន្មានហើយបងមានដឹងទេ?

ខៈ គាត់អាយុ80ឆ្នាំគត់តែម្តង

កៈ គាត់អាយុ80ឆ្នាំគត់ចុះគាត់កើតនៅឆ្នាំណាបងមានដឹងទេ?

ខៈ ខ្ញុំមិនសូវដឹងទេ ខ្ញុំតែខ្លួនអែងនឹងខ្ញុំចាំមិនសូវច្បាស់ផង ល្មមម្តាយទៀតខ្ញុំម៉េចនឹងចាំទៅ

កៈ គាត់អាយុ80ឆ្នាំគត់វា ចឹងកើតនៅឆ្នាំ1938បងម្តាយរបស់បងហាស?

ខៈ បាទនឹងហើយ

កៈ ចុះគាត់កើតនៅភូមិអី ឃុំអីបងមានដឹងទេ?

ខៈ ម៉ែរបស់ខ្ញុំហោស នៅខាងតាកែវ

កៈ នៅខាងតាកែវណាបង ចុះភូមិ ឃុំបងមានស្គាល់ទេបង?

ខៈ ខ្ញុំអត់ស្គាល់ទេ

កៈ អទ់ស្គាល់ទេណាបង ចុះស្រុកវិញបង?

ខៈ ស្រុកកំណើតរបស់គាត់នៅខេត្តតាកែវនឹងតែម្តង

កៈ អូចុះលក្ខណះថាគាត់កើននៅឆ្នាំ ជូត ឆ្លូវ ខាល ថោះអីបងមានដឹងទេ?

ខៈ អត់ដឹងទេ

កៈ អូអត់ដឹងទេណាបង ចុះឪពុករបស់បងគាត់មានឈ្មោះអីគេដែរបង?

ខៈ អូឪពុករបស់ខ្ញុំនឹង ខ្ញុំមិនបានឃើញមុខទេ

កៈ ចុះគាត់មានឈ្មោះអីគេដែរបង?

ខ៖ គាត់មានឈ្មោះវ៉ាត

ក៖ គាត់ឈ្មោះ វ៉ាត ចុះគាត់អាយុប៉ុន្មានបងមានចងចាំទេ?

ខ៖ អត់ទេ

ក៖ ចុះគាត់......?

ខ៖ ខ្ញុំមិនបានទាំងឃើញមុខគាត់ផងនឹង

ក៖ សូម្បីតែគាត់កើតនៅឆ្នាំអីក៏បងអត់ដឹងដែរណាបង?

ខ៖ បាទអត់ដឹងទេ ខ្ញុំបានឃើញមុខគាត់ផងនឹង

ក៖ ចុះគាត់កើតនៅណាបងមានស្គាល់ទេបង?

ខ៖ អត់ដែរនឹង

ក៖ ចុះសំរាប់ឪពុករបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរបងមានដឹងទេ?

ខ៖ កាលពីគាត់នៅរស់ហោស គាត់ធ្វើពេទ្យ

ក៖ គាត់ធ្វើពេទ្យណាបង?

ខ៖ គាត់ធ្វើពេទ្យហោយនឹងជាងម៉ាស៊ីនភ្លើង ជាអាជីពរបស់គាត់

ក៖ ចុះបងមានដឹងថាកាលពីគាត់នៅរស់នឹងគាត់ស្លូត រឺមួយក៏កាចបងមានដឹងទេបង?

ខ៖ ខ្ញុំម៉េចដឹងបើខ្ញុំមិនបានឃើញមុខគាត់ដែរនឹង បើខ្ញុំកើតមកខ្ញុំមិនបានឃើញផងនឹង គាត់ស្លាប់បាត់ទៅហើយ

ក៖ បាទចុះម្តាយរបស់បងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតដែរបង?

ខ៖ ម្តាយរបស់ខ្ញុំរាល់ថ្ងៃគាត់រកលែងកើតហើយគាត់បាត់ការចងចាំអស់ទៅហើយ

ក៖ ប៉ុន្តែចុះពីមុនបងគាត់ធ្វើអីគេដែរបង?

ខ៖ ពីមុនគាត់ដើរបេះត្រកួនលក់

ក៖ ហើយគាត់ធ្វើអីគេទៀតបង?

ខ៖ អត់មានធ្វើអីផង

ក៖ និយាយគាត់បេះតែត្រកួនទេណបង?

ខ៖ បាទគាត់ដើរបេះតែត្រកួនចឹងទៅគ្រាន់តែចិញ្ចឹមជីវិតរបស់គាត់ហាស
ប៉ុន្តែឥឡូវគាត់រកលែងកើតបាត់ការចងចាំអស់ហើយនឹង
ដល់ចឹងអោយគាត់ទៅនៅជាមួយកូនគាត់ទៅ

ក៖ ចុះគាត់ជាមនុស្សបែបណាដែរបង?

ខ៖ ស្លូតណាស់ម្ដាយរបស់ខ្ញុំគាត់ស្លូតណាស់

ក៖ ចុះបងធ្លាប់អនុស្សាវរីយ៍អីជាមួយម្ដាយរបស់បងទេ ដូចជាគាត់ធ្លាប់ប្រើបង
រឺក៏ធ្លាប់ធ្វើអីជាមួយគាត់ដែរចឹងហាសបង?

ខ៖ អត់ផង

ក៖ ចុះបងធ្លាប់ទៅស្រែ ធ្លាប់ទៅផ្សារ រឺធ្វើអីទេ?

ខ៖ អត់ទេ

ក៖ កាលពីគាត់នៅអត់ទាន់ចាស់ហាស?

ខ៖ អត់ដែរទេ ពីព្រោះគាត់ទៅចោលខ្ញុំរហូតនឹង

ក៖ ម៉េចចឹងបង?

ខ៖ គាត់នៅផ្ទះគាត់ដើរចាញ់បោកគេដីនៅភ្នំពេញគាត់ច្រើនណាស់
គាត់ចាញ់បោកគេគេលួងគាត់គេបោកគាត់ស៊ីចាយតាមគេអស់ទៅហើយខ្ញុំគាត់ទំលាក់ចោ
លទៅដល់ពេលនឹងទៅគាត់អត់កន្លែងជ្រកគាត់ស្ដាយទៅ

ក៖ គាត់មករកយើងវិញទៅ?

ខ៖ បាទគាត់ស្ដាយគំនិតគាត់

ក៖ អូប៉ុន្តែឥឡូវគាត់នៅកោះធំនៅជាមួយបងស្រីរបស់បង?

ខ៖ បាទនៅជាមួយកូនប្រុសរបស់គាត់

កៈ នៅជាមួយកូនប្រុសរបស់ហោស ចឹងម្ដាយរបស់បងគាត់មានកូន2នាក់ហោសបង មានកូនផ្សេងទៀតរឺមួយក៏យ៉ាងម៉េចដែរបង?

ខៈ អត់ទេកូនតែមួយនឹង

កៈ អូកូនតែមួយកូនប្រុសរបស់គាត់នឹងត្រូវជាបងប្រុសរបស់បងណាបង?

ខៈ បាទៗបងប្រុសរបស់ខ្ញុំ

កៈ អូបងចុះបងជាកូនទីប៉ុន្មានដែរបង?

ខៈ ខ្ញុំជាកូនទី4

កៈ បងជាកូនទី4ហោសបង
ចុះម្ដាយរបស់បងគាត់មានធ្លាប់ប្រាប់ពីប្រវត្តិគាត់ទៅបងទេបង?

ខៈ អត់ទេ

កៈ គាត់មិនដែរបានប្រាប់ថាកាលពីក្រមុំគាត់ធ្វើអីទេ?

ខៈ អត់ដែរទេ

កៈ អូបាទចុះបងមានស្គាល់យាយតានៅខាងម្ដាយទេបងស្គាល់ឈ្មោះគាត់ទេ?

ខៈ អត់ទេ អត់ស្គាល់ទេគាត់មិនបានប្រាប់ទេ

កៈ អូគាត់មិនដែរបានប្រាប់ទេណ ចុះខាងឪពុកវិញបងស្គាល់ទេ?

ខៈ អត់ស្គាល់ដូចគ្នានឹង បើមិនបានឃើញមុខគាត់ផងបានអីស្គាល់គាត់ទៅ

កៈ អូចឹងថ្ងៃខែឆ្នាំអីក៏បងអត់ដឹងដែរ?

ខៈ អត់ទេ

កៈ ចុះបងមកនៅទីក្រុងភ្នំពេញនឹងយូរនៅបង?

ខៈ ស្រុកកំណើតខ្ញុំនៅភ្នំពេញនឹងតែ ខ្ញុំកើតនៅភ្នំពេញនឹងតែម្ដងនឹង

កៈ ចឹងមានន័យថាបងនៅនឹងចង់35ឆ្នាំហើយណាបង បាទបង
ចុះបងមានសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសទេបង?

ខ៖ អត់មានទេ

ក៖ អត់មានបងប្អូនណាដែររស់នៅប្រទេសថៃ វៀតណាមអីទេហោស?

ខ៖ អត់អត់មានទេ

ក៖ អត់មានទេបង ចឹងចុះភរិយារបស់បងគាត់មានឈ្មោះអីគេដែរបង?

ខ៖ ឈ្មោះ ម៉េង វី

ក៖ ឈ្មោះម៉េង វីណាបង ចុះបងរៀបអាពាហ៍ពាពិហ៍នៅពេលណាដែរបង?

ខ៖ បានគ្នាយូរហើយបានគ្នជិត10ឆ្នាំហើយ

ក៖ អូបានជិត10ឆ្នាំហើយចឹងមានន័យថាបងរៀបអាពាហ៍ពិពាហ៍នៅឆ្នាំ2007-2008ហើយណាបង?

ខ៖ បាទនឹង10ឆ្នាំ ហើយគិតមើល10ឆ្នាំទាំងនឹងហើយ

ក៖ អស់10ឆ្នាំ នៅឆ្នាំ2008ចឹងថ្ងៃខែបងចាំទេ?

ខ៖ អត់បានចាំទេ

ក៖ អត់ចាំទេណាបង
ចុះនៅពេលដែររៀបអាពាហ៍ពិពាហ៍នឹងគិតថាបងជាអ្នករៀបចំដោយខ្លួនអែងរឺមួយក៏ឪពុកម្តាយជាអ្នករៀបចំអោយដែរបង?

ខ៖ ខ្ញុំរៀបចំដោយខ្លួនអែងនឹង

ក៖ អូបងរៀបដោយខ្លួនអែងណាបង ចុះបងមានជាបណ្ណាការទេបង
លក្ខណះថាហៅជាជំនូនហាសមានទេបង?

ខ៖ មានតាបង

ក៖ មានដូចជាប៉ុន្មានដែរបង?

ខ៖ មានតិចតួចនឹង

ក៖ កាលពីបងចូលទៅបងស្រីហាស?

ខ៖ បាទខ្ញុំចូលសែនបន្តិចបន្តួចនឹង គ្រាន់តែមានលោកសូត្រមន្តអីត្រឹមត្រូវដែរ

ក៖ ចុះបងអាចប្រាប់ខ្ញុំថាបងស្គាល់បងស្រីនៅពេលណាដែរទេបង?

ខ៖ ស្គាល់នៅតាមអ្នកជិតខាង

ក៖ អូអ្នកជិតខាងហោសបង
ប៉ុន្តែបងស្រលាញ់បងស្រីប៉ុន្មានខែដែរបានបងចូលទៅស្ដីគាត់ហាស?

ខ៖ លួមបាន5ខែហោសលួចមើលគេរហូតនឹងលួមបានគ្នា

ក៖ អូលួចមើលគាត់រហូតតែម្ដងហោសបង?

ខ៖ ហើយបងប្អូនជិតខាងនៅផ្ទះគាត់នឹង ថាអោយគាត់ជួយធ្វើមេអណ្ដើកអោយ

ក៖
បងអាចប្រាប់ពីប្រវត្តិស្នេហាបងថាហេតុអីបានបងស្គាល់គ្នាហើយបងស្គាល់តាមរយះអីចឹង
?

ខ៖ អត់ទេ

ក៖ អត់មានទេណាបង?

ខ៖ បានអីបងប្អូនជួយធ្វើមេអណ្ដើកអោយនឹងអ្នកស្គាល់គ្នា
ដូចអ្នកជិតខាងយើងជិតស្និទ្ធចឹងហាស
ហើយខ្ញុំមកលេងផ្ទះគាត់ហូបបាយហូបអីផ្ទះគាត់ចឹងទៅ
ក៏ស្គាល់គ្នារាប់អានតាំងពីតូចៗមក
ហើយខ្ញុំអោយគេជួយធ្វមេអណ្ដើកអោយខ្ញុំនឹងជួយនិយាយខ្ញុំទៅ
ហើយដល់ពេលដែរបានគ្នាចឹងទៅចាប់សែនបណ្ដោយចឹងទៅ

ក៖ អូចឹងហោសបង?

ខ៖ ហើយមុននឹងបានគ្នានឹងគន់មើល4-5ខែហើយនឹង

ក៖ អូយើងនៅមើលគ្នាសិនណាបង?

ខ៖ បាទបានបានសែននឹង

កៈ ប៉ុន្តែបងស្រីក៏ស្រលាញ់បងដែរណបង?

ខៈ បាទគេធ្វើការងារយប់នឹង

កៈ ប៉ុន្តែគាត់ធ្វការងារជាមួយបងដែររឺក៏អត់ទេបង?

ខៈ អត់ទេខ្ញុំធ្វើការងារផ្សេងគាត់ធ្វើផ្សេងនឹង ប៉ុន្តែខ្ញុំមកលេង

កៈ អូមកលេងផ្ទះគាត់ហោសបង?

ខៈ ប៉ុន្តែខ្ញុំមកលេងបងប្អូនរបស់ខ្ញុំមិត្តភក្តិជិតស្និទ្ធិចឹងហាស ហើយផ្ទះគាត់នៅជាប់ៗគ្នាចឹង បាទខ្ញុំមកលេងផ្ទះនឹងហាស ហើយខ្ញុំអោយមិត្តភក្តិជួយធ្វើមេអណ្តើកអោយនឹង ហើយក៏ខ្ញុំស្រលាញ់គ្នាចឹងទៅវាចឹងហាស

កៈ បាទបង ចុះបងចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរបង?

ខៈ អត់អត់ចេះផង អត់ដែរបានរៀនតែម្តង

កៈ បងអត់ដែរបានរៀនតែម្តងនឹងហោស ចុះបងមានចេះភាសាអីក្រៅពីភាសាខ្មែរទេបង?

ខៈ អត់អត់ចេះទេ

កៈ ចុះភាសាចិន ថៃ វៀតណាមអីបងចេះទេ?

ខៈ អត់ចេះទេ តែអក្សរខ្មែរមិនចេះផងអោយចេះភាសាអី

កៈ អត់ទេពេលខ្លះឡបងអត់ចេះខ្មែរប៉ុន្តែបងចេះភាសាអីផ្សេងហាស?

ខៈ អត់ទេ ប៉ុន្តែប្រពន្ធរបស់ខ្ញុំចេះ

កៈ គាត់ចេះភាសាអីគេដែរបង?

ខៈ គាត់ចេះភាសាអង់គ្លេស

កៈ អូគាត់ចេះភាសាអង់គ្លេសច្រើនហោសបង?

ខៈ បាទពីព្រោះអីគាត់ធ្វើការងារហ៊ាងបារាំងហាស គាត់ចេះនិយាយបារាំង

កៈ គាត់ចេះបារាំងទៀត ?

ខ៖ គាត់បានចេះ ខ្ញុំអត់ចេះទេ

ក៖ អូឡូវ ចុះគាត់មានចេះភាសាអីផ្សេងទៀតទេបង?

ខ៖ អត់ទេ

ក៖ គាត់ចេះតែខ្មែរ ?

ខ៖ ខ្មែរគាត់អត់ចេះទៀត

ក៖ អូចឹងគាត់ចេះតែអង់គ្លេស នឹងបារាំង គាត់ខ្លាំងហើយចឹង?

ខ៖ គាត់ចេះតែបារាំងសុទ្ធតែម្តង បើអោយសរសេរអក្សរខ្មែរអត់ចេះទេ

ក៖ ប៉ុន្តែគាត់ចេះសរសេរអក្សរអង់គ្លេសនឹងអក្សរបារាំងអត់បង?

ខ៖ អត់ចេះសរសេរទេ តែបើនិយាយរឹលតែម្តង

ក៖ ប៉ុន្តែទៅធ្វើការងារតាំងពីក្មេងៗមែនបង?

ខ៖ អត់ដឹងដែរនឹង

ក៖ អូគាត់មិនដែរប្រាប់ផងហោស?

ខ៖ គាត់ទៅធ្វើការងារតាមពួកម៉ាក់មិនមែនធ្វើតាំងពីក្មេងទេ ទើបតែឥឡូវនឹងដែរនឹង

ក៖ បាទបងចុះបងមានមិត្តភក្តិណាដែរធំធាត់តាំងពីក្មេងរហូតមកដល់ពេលនេះទេបង?

ខ៖ អត់មានផងនឹង

ក៖ ចុះបងមានធ្លាប់មានមិត្តភក្តិណាដែរធ្លាប់លេងជាមួយគ្នាកាលនៅក្មេងអត់បង?

ខ៖ អត់មានទេបែកបាក់គ្នាអស់ហើយ

ក៖ ចឹងអ្នកនៅភូមិជិតៗគ្នាអីចឹងហាសបង?

ខ៖ មានតែឥឡូវនឹងបែកបាក់គ្នាអស់ហើយនឹង

ក៖ ចុះបងអាចប្រាប់ឈ្មោះខ្លះៗបានទេដូចជាមានឈ្មោះអីៗខ្លះចឹងហាស?

ខ៖ អត់បានចាំទេយូរដែរហើយនឹង

កៈ អូម្នាក់ពីរនាក់ក៏បងអត់ចាំដែរណាបង?

ខៈ អត់ចាំទេ

កៈ
ចុះកាលពីនៅក្មេងៗបងចូលចិត្តលេងអីជាមួយមិត្តភក្តិបងនៅតាមភូមិតាមអីចឹងហាសបង ដូចជាលេងគបឈូសអីចឹងទៅ?

ខៈ លេងបោះអង្គុញ លេងលាក់កន្សែងចឹងទៅ លេងដណ្តើមស្លឹកឈើ

កៈ ប៉ុន្តែបងមានធ្លាប់លេងកូនប៉ែង លេងមឹក លេងខ្វងអីទេបង?

ខៈ បាទធ្លាប់តា

កៈ លេងគបឈូស លេងលក្ខណះថាលេងបាញ់ឃ្លីអីបងមានធ្លាប់ទេ?

ខៈ បាទធ្លាប់តា

កៈ ធ្លាប់លេងបិទពួនអីដែរតាហីបង លក្ខណះថាលេងស៊ីញ៉េហាសបង?

ខៈ បាទធ្លាប់លេងតា

កៈ អូបាទបង ចុះបងមានធ្លាប់តៅធ្វើការងារនៅវាលស្រែទេបង?

ខៈ ធ្លាប់តាបង

កៈ ធ្លាប់ណាបង ចុះបងទៅធ្វើការនៅវាលស្រែបងធ្វើអីគេដែរបង?

ខៈ ដូចជាទៅឃ្វាលគោ ដូចជាទៅដកសំណាប ទៅជញ្ជូនសំណាបអោយគេស្ទូងចឹងទៅ ការងាររបស់ខ្ញុំមានតែប៉ុណ្ណឹងអែង

កៈ ប៉ុន្តែបងមានធ្លាប់ច្រូតអីអត់បង?

ខៈ អាច្រូតខ្ញុំមិនដែរទៅច្រូតទេ ខ្ញុំអត់ចេះទេប៉ុន្តែបានជញ្ជូនសំណាបអោយគេ នឹងដកសំណាបបាន

កៈ ប៉ុន្តែនឹងមិនមែនស្រែរបស់យើងទេណាបង?

ខៈ មិនមែនទេខាងបងប្អូននឹង

កៈ ប៉ុន្តែគេជួលយើងទៅណាបង?

ខៈ អត់ទេនៅជាមួយបងៗនឹង
នៅជាមួយបងៗនៅខេត្តហើយខ្ញុំជួយបងៗចឹងទៅណាទៅមើលគោ
ដូចជាទៅជួយជញ្ជូនសំណាបអោយគាត់ចឹងទៅ ទៅជួយគាត់ហាស

កៈ បាទបងចុះបងមានធ្លាប់អាជីវកម្មអីទេបង?

ខៈ អត់ទេ

កៈ ចុះបងធ្លាប់មានចិញ្ចឹមសព្វទេ មានចិញ្ចឹមមាន់ ទា ជ្រូក គោអីចឹងហាសបង?

ខៈ អត់ដែរទេ

កៈ អត់ទេណបង ចុះគិតថាជំនាញអីដែរបងគិតថាបងចេះដែរបង?

ខៈ ពិបាកទៀតនឹងហាស

កៈ ដូចជាធ្វើសំណង់ធ្វើអីចឹងហាស?

ខៈ ដូចជាជំនាញធ្វើសំណង់

កៈ ជំនាញខាងធ្វើសំណង់ហោសបង ដូចជាខាងសំណង់បងចេះធ្វើអីគេដែរស្ទាត់ដែរបង?

ខៈ ដូចជារៀបឥដ្ឋ បូកដូចជាំលាយកំបោ៊

កៈ លាយកំបោ៊ បូក ចុះលក្ខណៈថាដូចជាមេជាងអីបងចេះទេ?

ខៈ អត់ទេ និយាយរួមទៅបានត្រឹមកម្មករគេនិង

កៈ ចុះមេការគេអោយធ្វើអីទៅបង?

ខៈ និយាយរួមទៅមេការគេមិនសូវអោយធ្វើអីទេនឹងបញ្ហាតែកូនចៅដែរនឹង

កៈ អូបញ្ហាតែកូនចៅដែរហោសបង?

ខៈ បញ្ហាដែរពីព្រោះអីគេជាអ្នកម៉ៅការហាស អង្គុយបញ្ជាគេនឹង

កៈ ប៉ុន្តែធ្វើម៉េចបានធ្វើដល់មេការហោសបង?

ខ៖ គេចេះប្រាជ្ញា

ក៖ គេចេះច្រើនជាងយើងហាសបង?

ខ៖ បាទគេចេះដឹងដែរគេការងារគេយល់
ប៉ុន្តែយើងកម្មករយើងមិនសូវយល់យើងធ្វើកម្មករគេទៅ

ក៖ ចឹងយើងធ្វើតាមគេចឹងទៅ
ចុះបងគិតងថាបងធ្លាប់ធ្វើការងារអីគេខ្លះនៅក្នុងជីវិតរបស់បងតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?

ខ៖ ថ្លាប់តែធ្វើសំណង់បង

ក៖ ធ្លាប់ធ្វើសំណង់ ?

ខ៖ ដូចជាម៉ៅបឹងឈូក ម៉ៅអីចឹងទៅ ដក់ខ្សារឈូក ដកអីចឹងហាស
ដូចជាបេះត្រកួនម៉ៅត្រកួនអីគ្រប់យ៉ាងអីទាំងអស់នឹង ដូចជាដើររើសអេតចាយ
ដើរទិញអេតចាយក៏មានដែរ

ក៖ អូបងដើរទិញអេតចាយដែរណាបង ចឹងមានន័យថាជំនាញរបស់បងគឺបេះត្រកួន

ខ៖ ធ្វើទាំងអស់នឹង

ក៖ និយាយរួមធ្វើអីក៏បានដែរអោយតែបានលុយណាបង?

ខ៖ បាទត្រូវហើយ

ក៖ អូល្អបង
ចុះតាំងពីក្មេងរហូតមកដល់ពេលនេះបងគិតថាជីវិតរបស់បងមានការផ្លាស់ប្តូរអីគេខ្លះដែរបង?

ខ៖ ដូចជាអត់មានឡើងទៅណាសោះបងដូចជានៅដដែលនឹង

ក៖ ចុះកាលពីក្មេងដូចជាចេះតែលេងអីចឹងហាស អត់ចេះរកលុយ?

ខ៖ ដឹងតែចាយសុំលុយបងចឹងទៅ ទៅសុំលុយម៉ែអីចឹងទៅ

ក៖ បាទបងដល់ពេលដែរមានប្រពន្ធទៅចាប់ផ្តើមរកលុយទៅ?

ខ៖ ចាប់ផ្ដើមចេះគិតរឿងប្រពន្ធកូនចឹងទៅ

ក៖ បាទបងនេះជាការផ្លាស់ប្ដូរនៅជីវិតរបស់បងហាស?

ខ៖ បាទមិនអាចដើរចាយនៅខ្ចីខ្ចៀដូចនៅកំលោះបានទេ មានប្រពន្ធគិតផ្សេងទៀត

ក៖ បាទបងចុះម្ហូបអីដែរបងចូលចិត្តតាំងពីក្មេងរហូតមកដល់ពេលនេះហាសបង?
ខ៖ អីក៏ខ្ញុំហូបដែរនឹង

ក៖ ចុះបងគិតថាម្ហូបអីដែរបងគិតថាបងគិតច្បាស់ជាងគេហាស ដែរបងនឹកឃើញហាស?

ខ៖ ដូចជាសាច់រលីង ហើយឆា ក្ដៅចឹងទៅម្ហូរគ្រឿងបាទអានឹងសំខាន់បំផុតហើយនឹង

ក៖ ចុះឆា ចៀន ស្ងោរអីចឹងហាសបង?

ខ៖ ហោយសាច់គោងៀតចឹងទៅ សាច់គោចៀនទៅ

ក៖ ចុះការីអីបងចូលចិត្តទេ?

ខ៖ ដូចជាការីនំប៉័ងអីចឹងទៅ

ក៖ នឹងជាម្ហូបដែរបងចូលចិត្តហើយណាបង?

ខ៖ បាទនឹងហើយ

ក៖
អូបាទចុះល្បែងប្រជាប្រិយ៍អីដែរបងគិតថាបងចូលចិត្តលេងតាំងពីក្មេងរហូតមកដល់ពេល
នេះហាសបង ដូចជាចោលឈូង លាក់កន្សែង បោះអង្គុញ
ពង្រត់កូនក្រមុំអីចឹងហាសបងនឹងបងចូលចិត្តលេងទេបង?

ខ៖ បាទចុលចិត្តតា

ក៖ ចូលចិត្តលេងអីជាងគេដែរបង?

ខ៖ ចូលចិត្តលេងលាក់កន្សែង បោះឈូងអីចឹងទៅ នឹងបោះអង្គុញ

ក៖ ភាគច្រើនបងចូលចិត្តលេងនៅណាដែរបង?

ខ. នៅតាមភូមិ នៅតាមជិតភូមិអីចឹងទៅណា ជួនកាលតាមវត្តចឹងទៅណា

កៈ គេលេងនៅពេលដែរជិតចូលឆ្នាំមែនទេបង?

ខៈ បាទជិតចូលឆ្នាំនឹងហើយពេលដែរចូលឆ្នាំចឹងទៅនៅពេលដែរបុណ្យទាន ខែបុណ្យទានហាស

កៈ ចុះបងមានចងចាំបទចំរៀងណាដែរបងចងចាំតាំងពីក្មេងរហូតមកដល់ពេលនេះទេ?

ខៈ អត់ទេ

កៈ ប៉ុន្តែបងចេះច្រៀងទេបង?

ខៈ អត់ទេ បើអត់ចេះអក្សរផងអោយច្រៀងអីកើតទៅ

កៈ អូគីឡូពេលខ្លះយើងចាំតាមគេច្រៀងអីចឹងហាស?

ខៈ បើចាំក៏ចាំបានខ្លះដែរនឹង

កៈ ប៉ុន្តែភាគច្រើនបងចាំបទចំរៀងនឹងអីគេដែរបងចំណង់ជើងវាហាសបង?

ខៈ បទហួសពេលហើយអូន ហើយសន្យាហើយថ្លៃ ហែកបេះដូង

កៈ សន្យាហើយថ្លៃ អូបងចេះហែកបេះដូងទៀតហោសបង
បងអាចដាក់មួយឃ្លាបានទេបង?

ខៈ អត់ទេគោកចឹងមិនអាចទៅរួចទេ

កៈ អូនិយាយលេងទេ គិតថាបងចូលចិត្តបទសម័យរឺមួយក៏បទបុរាណដែរបង?

ខៈ ខ្ញុំចូលចិត្តបទសម័យបង

កៈ បទសម័យណាបង បុរាណបងមិនសូវចូលចិត្តទេណាបង
ចុះបងមាននរណាម្នាក់នៅក្នុងក្រុមគ្រួសាររបស់បងចេះលេងឧបករណ៍ភ្លេងខ្មែរ ឃឹម គោះវៃដែរទេបង?

ខៈ អត់ចេះទេ

កៈ អត់ទេណាបង
ចុះផ្ទះរបស់បងមានលក្ខណៈបែបណាដែរតាំងពីក្មេងរហូតមកដល់ពេលនេះហាស
ពីក្មេងផ្ទះយ៉ាងម៉េចដែរបង?

ខៈ ខ្ញុំនៅផ្ទះនឹងហាស?

កៈ កាលពីនៅក្មេងហាសបង?

ខៈ ធម្មតាបង

កៈ នៅជាមួយម៉ាក់ប៉ាណាបង ប៉ុន្តែនៅលក្ខណៈផ្ទះឈើ រឺក៏ផ្ទះថ្មដែរបង?
ខៈ ផ្ទះឈើបងផ្ទះឈើ

កៈ ផ្ទះឈើណាបងប៉ុន្តែនៅទីក្រុងភ្នំពេញនឹងមែនទេបង?

ខៈ បាទនៅភ្នំពេញនឹង កាលពីខ្ញុំនៅតូចនឹង កាលណុងមិនសូវជាមានផ្ទះថ្មទេ
មានតែផ្ទះឈើនឹង ផ្ទះគៀ្បងអីចឹងហាសបង?

កៈ ប៉ុន្តែឥឡូវផ្ទះយ៉ាងម៉េចដែរបង?

ខៈ ប៉ុន្តែឥឡូវគេឡើងផ្ទះថ្មហើយ

ក. ប៉ុន្តែបងនៅជាមួយប្រពន្ធរបស់បងផ្ទះថ្មណាបង?

ខៈ អត់ទេខ្ញុំនៅជាមួយប្រពន្ធរបស់ខ្ញុំនឹងសុទ្ធតែក្រដៃនឹងខ្ញុំដើរជួលផ្ទះគេនៅទេ
គ្មានផ្ទះខ្លួនអែងទេខ្ញុំជួលផ្ទះគេនឹង
ឥឡូវនឹងខ្ញុំគ្មានសមត្ថភាពលុយអោយផ្ទះរបស់គេឥឡូវនឹងគេអោយចេញហើយ

កៈ អូម៉េចចឹងបង?
ខៈ គេអោយនៅខែនឹង ខែក្រោយគេអោយចេញហើយ

កៈ អូចឹងយើងទៅណាវិញទៅបង?

ខៈ ដើរទៅរកធ្វើសំណង់បង ចេះតែដើរទៅបងជីវិតអោយតែរកលុយបាន
អោយតែបានចិញ្ចឹមជីវិតចេះតែដើរទៅណា

កៈ ធ្វើចឹងល្អចេះជាងគេថាយើងធ្វើអីមួយមិនល្អដូចជាទៅឆក់ ប្លន់គេណាបង?
ខៈ អត់ទេបង

កៈ ចុះកាលពីបងនៅផ្ទះជាមួយឪពុកម្ដាយរបស់បងហាស
តើនរណាគេជាអ្នកសាងសងផ្ទះនឹងដែររឺមួយក៏ យើងជួលគេដែរបង?

ខៈ បងធ្វើដោយខ្លួនអែងនឹង

កៈ អូគាត់ចេះធ្វើផ្ទះហោសបង ចុះគាត់ចេះមកពីនរណាគេដែរបង?

ខៈ គាត់ចេះគំនិតខ្លួនគាត់នឹង

កៈ អូគាត់ទៅមើលគេចឹងគាត់ចេះធ្វើ?
ខៈ គាត់មានគំនិតគាត់នៅមើលគេចឹងគាត់ចេះហាស
ការងាររបស់គាត់មើលទៅគាំត់យល់តែម្ដងហាសបងគាត់យល់ទៅគាត់អាចធ្វើបាន
អ្នកខ្លះមើលយល់តែធ្វើអត់កើតទេថាប៉ុណ្ណឹងលូង់អីហាសការងារប៉ុណ្ណឹងសោះនឹងប៉ុន្តែអោយធ្វើធ្វើអត់កើតទេ អ្នកខ្លះគេយល់គេធ្វើកើតទៅវាចឹងបង

កៈ ចុះបងគិតថាធ្វើផ្ទះគេសាងសងផ្ទះគេប្រើឧបករណ៍អីគេខ្លះសំរាប់សាងសងផ្ទះដែរបង ផ្ទះរបស់បងនឹងហាសបង?

ខៈ ផ្ទះថ្មរឺមួយក៏ផ្ទះឈើ?

កៈ ផ្ទះឈើរបស់បងនឹង?

ខៈ ផ្ទះឈើមានតែ ដែកឈូស ពន្លាក់ ពូថៅ

កៈ មានដែកគោល រណា?

ខៈ បាទមានដែកគោល រណា ដែកគាស់ចឹងទៅ

កៈ បាទចុះសំរាប់ផ្ទះថ្មវិញគេមានអីគេខ្លះទៅបង?

ខៈ ផ្ទះថ្មគេមានស៊ីម៉ង់ ថ្មចឹងទៅត្រូវការប៉ែលស៊ីម៉ង់នឹង មានប៉ែល ស្លាបព្រា មានឥដ្ឋ

កៈ មានឥដ្ឋ មានស្លាបព្រា?

ខៈ បាទមានស្នូកអីទាំងអស់នឹង

កៈ
ចុះគិតថាជំនាញអីដែរបងគិតថាជាជំនាញដែរបងចេះស្ទាត់ជាងគេដែរបងដូចខាងធ្វើសំណង់ហាសបង?

ខៈ ខ្ញុំហោស ដូចជាលាយស៊ីម៉ង់ បៀកថ្នាំ

កៈ បៀកថ្នាំណាបង លក្ខណៈលាបឥដ្ឋមែនបង?

ខៈ អាថ្នាំជញ្ជាំប្រដាប់លាយថ្នាំពេត្រូយើងនេះនឹង ហើយនឹងថ្នាំបៀកៗយើងនឹង

កៈ ប៉ុន្តែរៀបឥដ្ឋបងចេះស្ទាត់ទេ?

ខៈ អោយរៀបឥដ្ឋមិនសូវចេះស្ទាត់ប៉ុន្មានទេ ប៉ុន្តែអាចធ្វើទៅបាន

កៈ ចុះឪពុកម្តាយរបស់បងគាត់ធ្លាប់មានបង្រៀនពីជំនាញ់អីទេបងទេ?

ខៈ អត់ផងនឹង

កៈ ចឹងអត់ទេណាបង?

ខៈ បាទអត់ទេ នេះខ្ញុំចេះគំនិតរបស់ខ្ញុំទេនេះនោះអត់មាននរណាគេបង្រៀនអីទាំងអស់នឹង

កៈ បាទចុះលក្ខណៈថាជំនាញវេញវល្លិ៍ កូរស្កត្នោត ធ្វើផ្តៅ ដេរកន្ទេលអីបងចេះទេ?

ខៈ អត់ទេ

កៈ អត់ទេហោសបង ចុះបងអាចប្រាប់ពីពេលលំបាករបស់បងអោយខ្ញុំដឹងផងបានទេបង តើនៅពេលណាចឹងហាសបង?

ខៈ បើនិយាយទៅវាវែងឆ្ងាយណាស់

កៈ បងអាចរៀបរាប់កាត់ក៏បានដែរតាមអ្វីដែរបងនឹកឃើញចឹងហាសបង
អាចប្រាប់ខ្ញុំបានទេ?

ខៈ និយាយទៅនិយាយអត់កើតទេខ្លាចទឹកភ្នែក

កៈ អូចុះកាលពីក្មេងបងពិបាកអីបន្តិចបន្តួច
ហើយឥឡូវបងពិបាកអីគេខ្លះដែរចឹងហាសបង?

ខ៖ ឥឡូវវេទនាជីវភាពរស់នៅវេទនាខ្លាំងតែម្តង វេទនាយ៉ាងម៉េចបងប្អូនអត់ជួយ រឺមួយក៏បងប្អូនកាត់ការចោលចឹងហាស

ក៖ អូចឹងហោសបង?

ខ៖ បាទសព្វថ្ងៃនឹងទោះខ្ញុំឈឺយ៉ាងម៉េចក៏ដោយក៏បងប្អូនអត់មានរវល់មើលខ្ញុំដែរនឹង តាមគេនឹកឃើញគេជួយបន្តិចបន្តួចចឹងទៅគេរំលើកមកវិញចឹងទៅ ចឹងបានខ្ញុំពីរនាក់ប្រពន្ធរបស់ខ្ញុំចេះតែដើរហើយនឹង ដើរកន្លែងណាល្អនៅកន្លែងនឹងទៅ

ក៖ បាទបងចុះបងឆ្លងការលំបាកនឹងដោយរបៀបណាដែរបង?

ខ៖ ប្រវត្តិរបស់ខ្ញុំជូរចត់ណាស់បងអើយ

ក៖ អូពិបាកណាបង?

ខ៖ វេទនាពិបាកយ៉ាងម៉េចក៏ខ្ញុំធ្លាប់ឆ្លងកាត់អស់ហើយនឹង

ក៖ បាទបងចុះពេលណាដែរបងគិតថាជាពេលដែរបងសប្បាយជាងគេ នៅក្នុងឆាកជីវិតរបស់បងដែរបង?

ខ៖ សប្បាយជាងគេដើរចូលក្លិបរាំលេងចឹងទៅ ចូលការ៉ាអូខេបំបាត់ទុកខ្លះចឹងទៅ

ក៖ ទៅជាមួយក្រុមគ្រួសាររបស់បងហាសណាបង?

ខ៖ បាទៗរាំលេងអីចឹងទៅពីព្រោះប្រពន្ធរបស់ខ្ញុំគេចូលចិត្តសប្បាយចឹងហាស

ក៖ ចុះពេលដែរបងរៀបអាពាហ៍ពិពាហ៍ជាមួយប្រពន្ធរបស់បងគិតថាពេលណុងសប្បាយអត់បង?

ខ៖ បាទសប្បាយ

ក៖ សប្បាយខ្លាំងហោសបង ចុះបងធ្លាប់មានក្តីសង្ឃឹម រឺក្តីស្រម៉ៃទេពេលដែរបងធំឡើងហាសកាលពីតូចបងធ្លាប់មានក្តីស្រម៉ៃអីទេបង?

ខ៖ អត់ទេ

ក៖ ចុះបងគិតថាបងចង់ធ្វើជាគ្រូបង្រៀន ធ្វើពេទ្យ រឺធ្វើអីទេបង?

ខ៖ អត់ទេទោះចង់ក៏ទៅមិនរួចដែរ មនុស្សអត់ចេះអក្សរ ខ្ញុំមិនបានរៀនតើខ្ញុំអាចធ្វើអីកើតទៅ

ក៖ ប៉ុន្តែបងគិតថាបងចង់ធ្វើអីគេដែរកាលពីមុនហាសបង?

ខ៖ ដល់ពេលចឹងយើងអត់ចេះអក្សរចឹងយើងអាចបានត្រឹមដើរធ្វើសំណង់ចឹងអែងនឹង ដើរធ្វើជាជាងអីចឹងទៅណា ដើរធ្វើខ្ញុំគេ ដើរធ្វើការងារហ៊ាងអីចឹងទៅ បាទប៉ុណ្ណឹងបង

ក៖ បាទចុះបើចង់អោយផ្ដែផ្ដាំទៅកូនចៅជំនាន់ក្រោយៗតើបងចង់ផ្ដែផ្ដាំអីគេខ្លះទៅពួកគាត់ដែរបង?

ខ៖ ទៅក្មេងជំនាន់ក្រោយហោស ពិបាកនិយាយណាស់អត់ចេះនិយាយទេនេះ

ក៖ អត់ទេចង់និយាយថាផ្ដែផ្ដាំអោយពួកគាត់ខំរៀន រឺក៏មិនចង់អោយពួកគាត់ដើរផ្លូវខុសអីចឹងហាសបងមានអីទេ?

ខ៖ អោយក្មេងជំនាន់ក្រោយអោយខំរៀន គិតអនាគត់ទៅមុខកុំអោយវេទនាដូចខ្ញុំ ថាខ្ញុំវាជ្រុលហួសពេលទៅហើយ ខ្ញុំអត់បានចេះអក្សរអត់បានរៀនទេ ចឹងបានថាអោយក្មេងៗកុំអោយយកគំរូតាមខ្ញុំបាទអរគុណបានតែប៉ុណ្ណឹងអែង

ក៖ អូបាទបង ចឹងមានអីផ្សេងទៀតអត់បង?

ខ៖ អស់ហើយ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណខ្រើនបងដែរបានអោយខ្ញុំសំភាសន៍ពីប្រវត្តិរបស់បង ហើយខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាហាសបង ហើយខ្ញុំអរគុណច្រើនបង ហើយខ្ញុំចង់ជូនពរបងអោយមានសុខភាពល្អ ដើម្បីអោយក្រុមគ្រួសាររបស់បងមានការរីចំរើនជាងមុនចឹងហាសបង បាទចឹងអរគុណច្រើនបង៕៕៕